ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Mar-2011, 12:58
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសនីតិវិធី**

---

ដាក់ដោយ៖

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

ផ្ញើជូន៖

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម យូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

ផ្ញើជូន៖

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តទៅនេះសូមស្នើអង្គជំនុំជម្រះសាលាដំបូងលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី។ ញត្តិធ្វើឡើងជាចាំបាច់ ព្រោះដីកាដំណោះស្រាយមានចន្លោះខ្វះខាតជាច្រើន ជាពិសេសការអនុវត្តបទល្មើសជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ការទទួលខុសត្រូវរបស់ថ្នាក់លើ សហឧក្រិដ្ឋកម្មរួម (“JCE”) និងការធ្វើផែនការ ការញុះញង់ ការជួយនិងការជម្រុញ និងការបញ្ជា ។

I **ភាពអាចទទួលយកបាន**

១. ច្បាប់កម្ពុជា និង វិធានផ្ទៃក្នុងរបស់ អវតក (“វិធានផ្ទៃក្នុង”) មិនបាននិយាយពីការកំណត់ពេលវេលា និងនីតិវិធីសម្រាប់ការស្នើសុំឲ្យលុបចោល ឬ ធ្វើការកែប្រែផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារការមិនគោរពតាមវិធានបញ្ញត្តិនោះ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានបញ្ជាក់ថា “ចំពោះការជំទាស់ទៅនឹងការមិនគោរពតាមវិធានបញ្ញត្តិក្នុងទម្រង់ដីកាដំណោះស្រាយ អង្គបុរេជំនុំជម្រះយល់ឃើញថាការជំទាស់ទាំងនេះមិនមានលក្ខណៈជាបញ្ហាយុត្តាធិការយ៉ាងច្បាស់ ហើយហេតុដូច្នេះការជំទាស់ទាំងនេះមិនអាចទទួលបានទេនៅដំណាក់កាលមុនអង្គសេចក្តីនៃកិច្ចដំណើរការនីតិវិធី... ដូច្នេះ អំណះអំណាងទាំងនេះអាចដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ដើម្បីពិចារណាជាអង្គសេចក្តីនៅសវនាការជំនុំជម្រះក្តី...”[1]។

២. មេធាវីការពារក្តីពិចារណាថាពេលវេលាដ៏សមស្របដើម្បីលើកឡើងបញ្ហាទាំងនេះ គឺនៅពេលនេះនៅមុនសវនាការជំនុំជម្រះក្តីចាប់ផ្តើម។ ហេតុអ្វីបានលើកឡើងបញ្ហាទាំងនេះនៅពេលនេះ គឺដោយសារលោក អៀង សារី មានសិទ្ធិត្រូវបានជូនដំណឹងលម្អិតពីចរិតនៃបទចោទប្រឆាំងនឹងរូបគាត់[2]។ វានឹងមានប្រសិទ្ធិភាពបំផុត ដើម្បីលុបចោលចន្លោះខ្វះខាតនៃផ្នែកណាមួយនៃដីកាដំណោះស្រាយនៅពេលនេះ នៅមុនសវនាការជំនុំជម្រះក្តីចាប់ផ្តើម ។ ការធ្វើដូច្នេះនឹងជួយដល់ការគោរពសិទ្ធិរបស់លោក អៀង សារី ត្រូវជំនុំជម្រះក្តីដោយគ្មានការអូសបន្លាយពេលវេលា[3] ។

II. **អំណះអំណាង**

---

[1] *ករណី នួន ជា* 00២/១៩-0៩-២00៧-អវតក/កសចស/អជសជ, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០១១, D427/3/15, ERN: 00644462-00644571 នៅកថាខណ្ឌទី ៦៣ ។

[2] សូមមើលច្បាប់បង្កើត អវតក នៅមាត្រា ៣៥ថ្មី ។

[3] ដូចខាងលើ ។

### ក. បទល្មើសជាតិ

៣. អង្គជំនុំជម្រះសាលាដំបូង ត្រូវតែលុបចោលពីដីកាដំណោះស្រាយនូវការយោងចំពោះឧក្រិដ្ឋកម្មជាតិ ពីព្រោះពុំមានអង្គហេតុត្រូវបានចែងនៅក្នុងដីកាដំណោះស្រាយដើម្បីគាំទ្រដល់ការបញ្ចូលឧក្រិដ្ឋកម្មនេះ ហើយក៏ពុំបានដាក់បញ្ចូលនូវទម្រង់នៃការទទួលខុសត្រូវ ដែលអនុវត្តចំពោះឧក្រិដ្ឋកម្មទាំងនេះដែរ ។ ដីកាដំណោះស្រាយចែងពីអង្គហេតុដែលយកប្រើប្រាស់ដោយ កសចស ដើម្បីគាំទ្រការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ប៉ុន្តែ ដីកាដំណោះស្រាយមិនបានចែងពីអង្គហេតុ ដែលត្រូវបានពិចារណាដោយ កសចស ដើម្បីគាំទ្រដល់ការចោទប្រកាន់តាមមាត្រា ៣ថ្មី ដែលចែងពី ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និង អំពើធ្វើទុក្ខបុកម្នេញខាងសាសនា ។ លោក អៀង សារី មិនត្រូវបានជូនដំណឹងគ្រប់គ្រាន់ពីចរិត និងបុព្វហេតុនៃការចោទប្រកាន់ប្រឆាំងនឹងគាត់ទេ ។

៤. ដីកាដំណោះស្រាយក៏បានខកខានចែងពីទម្រង់នៃការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលអាចចោទប្រកាន់មកលើលោក អៀង សារី មានជាអាទិ៍ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម ឬ ការធ្វើទុកបុកម្នេញខាងសាសនា ។ ដីកាដំណោះស្រាយបានពិភាក្សាពីទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន តែ កសចស ពិភាក្សាពីសហឧក្រិដ្ឋកម្មរួម ការធ្វើផែនការ ការញុះញង់ ការជួយ និងការជម្រុញ ការបញ្ជា និងការទទួលខុសត្រូវជាថ្នាក់លើ[4] ។ កសចស យល់ឃើញថាទម្រង់នៃការទទួលខុសត្រូវទាំងនេះ អាចអនុវត្តចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរ ប៉ុន្តែ កសចស <u>មិន</u>បានបញ្ជាក់ថាទម្រង់នៃការទទួលខុសត្រូវទាំងនេះអនុវត្តចំពោះមាត្រា ៣ បទល្មើសថ្មីទេ[5] ។ បទល្មើសជាតិមិនត្រូវបានដាក់បញ្ចូលយ៉ាងពិតប្រាកដ ។ កសចស ធ្លាប់បានយល់ឃើញថាទម្រង់អន្តរជាតិនៃការទទួលខុសត្រូវ មិនអាចអនុវត្តចំពោះបទល្មើសជាតិបានទេ[6] ហើយការយល់ឃើញនេះមិនត្រូវបានបដិសេធដោយអង្គបុរេ-ជំនុំ

---

[4] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ D427, ERN: 00604508-00605246 (ដីកាដំណោះស្រាយ) នៅកថាខណ្ឌទី១៥២១-១៥៦៣ ។

[5] ដូចខាងលើ នៅកថាខណ្ឌ ១៥២៥, ១៥៤៥, ១៥៤៦, ១៥៤៨, ១៥៤៩, ១៥៥១, ១៥៥២, ១៥៥៤ និង១៥៥៥ ។

[6] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចលើការអនុវត្តនៅ អវតក នូវទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានគេស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ D97/13, ERN: 00411047-00411056 នៅ

ជម្រះឡើយ[7] ។

៥. ដោយសារទម្រង់នៃការទទួលខុសត្រូវមិនអាចអនុវត្តចំពោះបទល្មើសជាតិ ហេតុនេះដីកាដំណោះស្រាយគួរតែបានចែងថាតើទម្រង់នៃការទទួលខុសត្រូវថ្នាក់ជាតិមួយណាដែល កសចស ចាត់ទុកថាអាចអនុវត្តបាននោះ ។ បន្ទាប់មក ដីកាដំណោះស្រាយគួរតែបានពន្យល់ថាតើអង្គហេតុទាំងនោះនឹងត្រូវកំណត់ឈ្មោះបទល្មើសយ៉ាងដូម្តេច ។ ឧទាហរណ៍ ប្រសិនបើ កសចស ចាត់ទុកថាលោក អៀង សារី បានប្រព្រឹត្តមនុស្សឃាត ការធ្វើទារុណកម្ម ឬ ការធ្វើទុកម្នេញដោយផ្ទាល់មែន កសចស ត្រូវតែបានបញ្ជាក់នូវព័ត៌មានជាក់លាក់នៅក្នុងដីកាដំណោះស្រាយ ។ អង្គបុរេជំនុំជម្រះបានបញ្ជាក់ "នៅពេលចោទថាជនជាប់ចោទបានប្រព្រឹត្តបទល្មើសដែលជាចំណុចនៃការតវ៉ាដោយផ្ទាល់ អត្តសញ្ញាណជនរងគ្រោះ ទីកន្លែង និង កាលបរិច្ឆេទប្រហាក់ប្រហែលនៃបទល្មើសដែលបានចោទប្រកាន់ មធ្យោបាយនានាដែលប្រើប្រាស់ដើម្បីប្រព្រឹត្ត ត្រូវតែបានបង្ហាញ "ឱ្យបានច្បាស់លាស់"[8] ។

៦. ដោយសារតែដីកាដំណោះស្រាយ ខកខានមិនបានចែងអង្គហេតុដែលគាំទ្រដល់ការចោទប្រកាន់ពីបទធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញ និងខកខានមិនបានចែងទម្រង់នៃការទទួលខុសត្រូវដែលពាក់ព័ន្ធ និងអង្គហេតុដែលគាំទ្រដល់ការអនុវត្តទម្រង់នៃការទទួលខុសត្រូវនេះផ្នែកនៃដីកាដំណោះស្រាយដែលយោងទៅលើមាត្រា ៣ ឧក្រិដ្ឋកម្មថ្មី មិនមានសុពលភាពទេ ដោយការមិនគោរពវិធានបញ្ញត្តិ ។

## ខ. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

៧. អង្គជំនុំជម្រះសាលាដំបូងត្រូវលុបចេញពីដីកាដំណោះស្រាយនូវការយោងទាំងអស់ ចំពោះឧក្រិដ្ឋ-

---

កថាខណ្ឌទី ២២៦ "ទម្រង់នៃការទទួលខុសត្រូវសម្រាប់បទល្មើសអន្តរជាតិអាចអនុវត្តបានតែចំពោះបទល្មើសអន្តរជាតិប៉ុណ្ណោះ"

[7] *ករណី អៀង សារី* ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៣៥) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ D97/14/15 ERN: 00486521-00486589 (សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសហឧក្រិដ្ឋកម្មរួម) នៅកថាខណ្ឌទី១០២ ។

[8] ករណី កាំង ហ្គេកអ៊ាវ ០០១/១៨-០៧-២០០៧-អវតក/កសចស(អបជ០២) សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានបញ្ជូន ឌុច ទៅជំនុំជម្រះ ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨ D99/3/42, ERN: 00249846-00249887 ("សាលាដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍របស់ ឌុចប្រឆាំងនឹងដីកាដំណោះស្រាយ") នៅកថាខណ្ឌ ទី៤៩ (បញ្ជាក់បន្ថែម) ។

កម្មប្រល័យពូជសាសន៍ ពីព្រោះបទល្មើសនេះមិនត្រូវបានអនុវត្តត្រឹមត្រូវទេ ។ ដីកាដំណោះស្រាយ ចែងយ៉ាងត្រឹមត្រូវអំពីនិយមន័យរបស់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[9] ប៉ុន្តែ គេអនុវត្តនិយមន័យនេះ មិនត្រឹមត្រូវទៅវិញ ។ ដីកាដំណោះស្រាយបញ្ជាក់ក្នុងចំណោមបញ្ហាដទៃទៀតថា[10] "ចេតនារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា អាចត្រូវបានគេសន្និដ្ឋានដោយអង្គហេតុដែលថា អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ត្រូវបានកើតឡើងនៅក្នុងបរិបទនៃការធ្វើទុក្ខបុកម្នេញជនជាតិដែលចេះដែលកើនឡើង និងជាអំពើដែលសម្របសម្រួលដោយបក្សកុម្មុយនីស្តកម្ពុជា"[11] ហើយថា ចេតនារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា អាចត្រូវបានគេសន្និដ្ឋានដោយអង្គហេតុដែលថាអំពើប្រល័យពូជសាសន៍លើប្រជាជនវៀតណាម អាចកើតឡើងនៅក្នុងបរិបទនៃការនិរទេសដែលចេះតែកើនឡើង ការធ្វើទុក្ខបុកម្នេញ ការញុះញង់ឲ្យស្អប់ខ្ពើម និងការឃោសនាសង្គ្រាមប្រឆាំងវៀត-ណាមដែលសម្របសម្រួលដោយបក្សកុម្មុយនីស្តកម្ពុជា"[12] ។ កសចស ភាន់ច្រឡំនៅក្នុងការយល់ឃើញថាចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ អាចសន្និដ្ឋានបានដោយមិនចាំបាច់រកឃើញថា <u>វាគឺជាការសន្និដ្ឋានសមហេតុផលដោយផ្អែកលើភស្តុតាងដែលមាន</u> ។

៨. អនុលោមតាមយុត្តិសាស្ត្ររបស់តុលាការ ICTY ចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ "នៅក្នុងករណីគ្មានភស្តុតាងផ្ទាល់ច្បាស់លាស់ អាចសន្និដ្ឋានពីអង្គហេតុ និងកាលៈទេសៈជាច្រើន ដូចជាបរិបទទូទៅ ការប្រព្រឹត្តអំពើដទៃទៀតដែលមានលក្ខណៈជាប្រព័ន្ធ ប្រឆាំងនឹងក្រុមតែមួយ វិសាលភាពនៃអំពីព្រៃផ្សៃ ការដៅជាប្រព័ន្ធទៅលើជនរងគ្រោះ ដោយមូលហេតុសមាជិកភាពរបស់ពួកគេនៃក្រុមជាក់លាក់ ឬ ការប្រព្រឹត្តដដែលនូវអំពើបំផ្លិចបំផ្លាញ និងរើសអើង"[13] ។ ប៉ុន្តែការសន្និដ្ឋាននេះត្រូវបានអនុញ្ញាតតែនៅវាជាការសន្និដ្ឋាន "សមហេតុផលផ្អែកលើភស្តុតាងដែលមាន[14]" ។ នៅក្នុងករណី *Jelisic* អង្គជំនុំជម្រះសាលាដំបូងនៅ ICTY មិនអាចសន្និដ្ឋានថា

---

[9] ដីកាដំណោះស្រាយ នៅកថាខណ្ឌទី១៣១២ ។

[10] ដូចខាងលើ នៅកថាខណ្ឌទី១៣៤០, ១៣៤៧ ។

[11] ដូចខាងលើ នៅកថាខណ្ឌទី១៣៤១, (បញ្ជាក់បន្ថែម) ។

[12] ដូចខាងលើ នៅកថាខណ្ឌទី១៣៤៨, (បញ្ជាក់បន្ថែម) ។

[13] *រឿងក្តីរដ្ឋអាជ្ញា តទល់ Jelisic, IT-95-10-A,* សាលដីកាចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០១ នៅកថាខណ្ឌទី៤៧ ។

[14] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić*, IT-98-33-A, សាលដីកា, ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤, កថាខណ្ឌទី៤២ (សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Krstić*) សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Vasiljević*, IT-98-32-A, សាលដីកា, ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៤, កថាខណ្ឌទី១២០។

Jelisic មានចេតនា[15]ប្រល័យពូជសាសន៍ បើទោះបីជាអង្គជំនុំជម្រះរកឃើញថា៖

> Goran Jelisic ណែនាំខ្លួនគាត់ថាជា "Adolf របស់ Serb" និងបានអះអាងថាបានធ្វើដំណើរទៅតំបន់ Brcko ដើម្បីសម្លាប់ជនម៉ូស្លីម ។ ហើយគាត់ក៏បានបង្ហាញខ្លួនគាត់ថាជា Adolf នៅពេលបង្ហាញខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី២៦ ខែមករា ឆ្នាំ ១៩៩៨ ។ គាត់ត្រូវបានគេចោទប្រកាន់ថាបាននិយាយទៅកាន់អ្នកជាប់ឃុំនៅជំរុំឃុំខ្លួន Luka ថាជីវិតរបស់ពួកគេស្ថិតនៅក្នុងកណ្តាប់ដៃរបស់គាត់ ហើយថា អ្នកទោសតែ ៥ភាគរយ ទៅ ១០ ភាគរយ ប៉ុណ្ណោះ អាចចាកចេញពីជំរុំនេះ ។ អនុលោមតាមសាក្សីម្នាក់ទៀត Goran Jelisic បានប្រាប់អ្នកទោសម៉ូស្លីមនៅជំរុំឃុំខ្លួន Luka ថាអ្នកទោសម៉ូស្លីមចំនួន ៧០ ភាគរយ ត្រូវបានសម្លាប់ ៣០ ភាគរយ ត្រូវបានវាយដំ ហើយថាអ្នកទោសតែ ៤ ភាគរយ ប៉ុណ្ណោះក្នុងចំណោមអ្នកទោស ៣០ ភាគរយ មិនត្រូវបានគេវាយដំធ្ងន់ធ្ងរ ។ Goran Jelisic ត្រូវបានកត់សម្គាល់ដោយសាក្សីម្នាក់ថាគាត់ស្អប់ខ្ពើមជនម៉ូស្លីម និងចង់សម្លាប់ពួកគេទាំងអស់ ហើយចំពោះជនម៉ូស្លីមដែលរួចផុតពីការសម្លាប់ អាចទុកឱ្យធ្វើទាសករសម្រាប់សំអាតបង្គន់ ប៉ុន្តែមិនត្រូវផ្តល់ការងារអាជីពទេ។ ត្រូវបានគេរាយការណ៍ថា Goran Jelisic ចង់បោសសំអាតជនម៉ូស្លីម ហើយគាត់រីករាយ ក្នុងការធ្វើកិច្ចការនេះ ហើយថា balijas បានសាយភាយយ៉ាងខ្លាំង ហើយថាគាត់ត្រូវតែកម្ទេចពួកគេឱ្យអស់ពីផែនដី ។ Goran Jelisic ត្រូវបានគេដឹងថាបាននិយាយថាស្អប់ខ្ពើមស្ត្រីម៉ូស្លីម ហើយគាត់យល់ឃើញថាពួកគេអាក្រក់ខ្លាំងណាស់ ហើយគាត់ចង់ធ្វើឱ្យពួកគេមិនអាចមានកូនបានដើម្បីទប់ស្កាត់ការកើនឡើងនៃជនម៉ូស្លីម ប៉ុន្តែយល់ឃើញថា មុនពេលសម្លាប់ពួកគេ គាត់នឹងចាប់ផ្តើមជាមួយមនុស្សប្រុសទាំងនោះសិនដើម្បីទប់ស្កាត់នូវការបង្កកំណើត [16]។

៩. មេធាវីការពារក្តីទទួលស្គាល់ថាការពិភាក្សាពី "បទដ្ឋានភស្តុតាង" នៅក្នុងដីកាដំណោះស្រាយ[17] ដែលក្នុងនោះ កសចស បានលើកឡើងថាខ្លួនត្រូវតែសម្រេចថាតើមាន"ភាវនីយភាពនៃពិរុទ្ធ"នៅក្នុងដំណាក់កាលនេះដែរឬទេជាជាងសម្រេចថាតើពិរុទ្ធនោះត្រូវបានរកឃើញ "ឱ្យហួសពីវិមតិសង្ស័យដែរឬទេ[18]"។ ករណីនេះ មិនអាចភ័ន្តច្រឡំនឹងការសម្រេចទាក់ទងនឹងការទាញសេចក្តីសន្និដ្ឋានដ៏

---

[15] សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Jelisić*, IT-95-10-T, សាលក្រមចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ១៩៩៩, កថាខណ្ឌទី ១០៧ ដល់ ១០៨។

[16] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី១២០។

[17] ដីកាដំណោះស្រាយ, កថាខណ្ឌ១៣២០ ដល់ ១៣២៦។

[18] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី១៣២៣។

សមហេតុផលតែមួយគត់ដែលមាននៅលើភស្តុតាងបានឡើយ។ យោងតាមយុត្តិសាស្ត្ររបស់តុលាការ ICTY "ភស្តុតាងបឋម (*prima facie*)... គឺជាភស្តុតាងដែលគួរឲ្យជឿជាក់ដែល (ប្រសិនបើមិនត្រូវបានជំទាស់ដោយមេធាវីការពារក្តីទេនោះ) ភស្តុតាងនេះ នឹងក្លាយជាមូលដ្ឋានគ្រប់គ្រាន់មួយដើម្បីវិនិច្ឆ័យលើជនត្រូវចោទលើបទចោទប្រកាន់ដែលមាន[19]" ។ ការទាញសេចក្តីសន្និដ្ឋានរបស់ កសចស មិនទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយទេដើម្បីកាត់ទោសលោក អៀង សារី ព្រោះ កសចស មិនបានបង្ហាញ ឬមិនបានសូម្បីតែព្យាយាមបង្ហាញថាការទាញសេចក្តីសន្និដ្ឋានរបស់ពួកគេ គឺមានលក្ខណៈសមហេតុផលតែមួយគត់។ យោងតាមបទដ្ឋានភស្តុតាងដែលដែលខ្លួនបានលើកឡើង កសចស ត្រូវបានគេតម្រូវក្នុងកម្រិតអប្បបរិមាឲ្យរកឲ្យឃើញលើលពីភវនីយភាពថាការទាញសេចក្តីសន្និដ្ឋានដ៏សមហេតុផលដែលថាលោក អៀង សារី មានបំណងជាក់លាក់ដើម្បីកំទេចទាំងស្រុង ឬជាផ្នែក នូវក្រុមមនុស្សដែលមានការការពារនោះ ។ ប៉ុន្តែ កសចស មិនបានធ្វើដូច្នេះឡើយ។ មិនមានភស្តុតាងបឋមក្នុងការអនុវត្តការចោទប្រកាន់ពីបទប្រល័យពូជសាសន៍ប្រឆាំងលោក អៀង សារី ទេ។ ដូច្នេះការយោងណាមួយទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ត្រូវតែលុបចេញពីដីកាដំណោះស្រាយ។

១០. ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថាកថាខណ្ឌខាងលើមិនចាំបាច់ត្រូវលុបចោល នោះ ដីកាដំណោះស្រាយ ត្រូវតែធ្វើការកែប្រែដើម្បីផ្តល់ការកត់សម្គាល់ឲ្យបានគ្រប់គ្រាន់ដល់លោក អៀង សារី ។ កសចស ភ័ន្តច្រលំព្រោះ កសចស ខកខានមិនបានបញ្ជាក់ថាតើបទឧក្រិដ្ឋប្រល័យពូជសាសន៍ដែលអាចផ្តន្ទាទោសបានមួយណា ដែលត្រូវបានគេចោទប្រកាន់ប្រឆាំងលោក អៀង សារី។ ច្បាប់ស្តីពីការបង្កើត អវតក បានបញ្ជាក់ថាការប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ការឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ គឺជាអំពើប្រល័យពូជសាសន៍ដែលអាចយកមកផ្តន្ទាទោសបាននៅ អវតក ។ ទម្រង់នីមួយៗនៃការចូលរួមទាំងនេះ មានធាតុផ្សំមួយចំនួនដែលត្រូវតែបានបង្កើតឡើង។ ឧទាហរណ៍ការឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ "មានធាតុផ្សំពីរដែលត្រូវលើកយកមកជជែកតវ៉ានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ៖ (i) ការព្រមព្រៀងរវាងបុគ្គលដែលមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និង (ii) ការពិតដែលថាបុគ្គលដែលចូលរួមក្នុងកិច្ចព្រម

---

[19] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី១៣២៥, ដកស្រង់រឿងក្តី *Kordić et al.*, , ការពិនិត្យមើលដីកាចោទប្រកាន់, ឆ្នាំ១៩៩៥ (គ្មានទំព័រ ឬលេខកថាខណ្ឌណាមួយ ឬការបរិច្ឆេទជាក់លាក់ ឬលេខសំណុំរឿង ត្រូវបានផ្តល់ឲ្យដោយ កសចស ឡើយ (គូសបញ្ជាក់បន្ថែម)។

ព្រៀងនោះ មានចេតនាបំផ្លាញទាំងស្រុង ឬមួយផ្នែកនូវក្រុមសាសនា ជាតិសាសន៍ ជាតិពន្ធុ ឬជាតិណាមួយ[20]" ។ ដីកាដំណោះស្រាយមិនបានលើកឡើងថាវាមានការព្រមព្រៀងជាក់ស្តែង ដើម្បីប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ ទោះបីជាដីកានេះបានលើកឡើងថាសមាជិក JCE ដែលយល់ស្របទៅលើគោលបំណងរួមដែលមិនបូកបញ្ចូលនូវអំពើប្រល័យពូជសាសន៍ <u>បានដឹង</u> អំពីការណ៍ដែលថា ការធ្វើឲ្យបានសម្រេចនូវផែនរួមរបស់ពួកគេត្រូវបានពន្លាតផងដែរដល់ការប្រព្រឹត្តអំពើប្រល័យពូជសាសន៍[21]ក៏ដោយ។ ដីកាដំណោះស្រាយក៏មិនបានលើកឡើងពីការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែរ។ ដីកាដំណោះស្រាយត្រូវតែធ្វើការកែប្រែដើម្បីឲ្យច្បាស់ថា លោក អៀង សារី មិនត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬឃុបឃិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ ។

## គ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

១១. ដីកាដំណោះស្រាយ មានកំហុសឆ្គងដែលលើកឡើងថា "ធាតុផ្សំនៃបទល្មើសប្រឆាំងមនុស្សជាតិក្រោមទម្រង់នៃការនិរទេស ត្រូវបានរកឃើញនៅក្នុងខេត្តព្រៃវែង និងស្វាយរៀង និងនៅក្នុងសហករណ៍ស្រុកត្រាំកក់[22]"។ ជាងនេះទៅទៀត "ជនជាតិវៀតណាមមួយភាគធំដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានបង្ខំឲ្យចាកចេញពីលំនៅដ្ឋានស្របច្បាប់របស់ខ្លួន និងឆ្លងទៅព្រំដែនវៀតណាម[23]" ។ វិធាន ៥៥ (២) នៃវិធានផ្ទៃក្នុងចែងថា៖ "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបអង្កេតតែអង្គហេតុណាដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមតែប៉ុណ្ណោះ[24]" ។ ផ្នែកនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលពិចារណាលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងខេត្ត

---

[20] *រឿងក្តីរដ្ឋអាជ្ញា* តទល់នឹង *Nahimana et al* , តុលាការ ICTR-99-52-A, សាលដីកា, ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧, កថាខណ្ឌទី៣៤៤ (គូសបញ្ជាក់បន្ថែម)។ សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Ntagerura et al,* តុលាការ ICTR-99-46-A, សាលដីកា, ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៦, កថាខណ្ឌទី៩២៖ "ការឃុបឃិតដើម្បី ប្រព្រឹត្តអំពើប្រល័យពូជសាសន៍ រួមមានកិច្ចព្រមព្រៀងរវាងបុគ្គលពីរ ឬច្រើននាក់ដើម្បីប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍"។ ដូច្នេះ អត្ថិភាពនៃកិច្ចព្រមព្រៀងបែបនេះ …គួរតែត្រូវបានបកស្រាយក្នុងដីកាចោទប្រកាន់ថាជាអង្គហេតុសត្យានុម័ត"។

[21] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥២៧។

[22] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១៣៩៨។

[23] ដូចជើងទំព័រខាងលើ។

[24] វិធាន៥៥(២) នៃវិធានផ្ទៃក្នុង។

ព្រៃវែង[25] ស្វាយរៀង[26] និងក្នុងសហការណ៍ស្រុកត្រាំកក់[27] មិនបានបញ្ជាក់ពីអង្គហេតុដែលលើកឡើងថា "ជនជាតិវៀតណាមមួយភាគធំដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវបានបង្ខំឲ្យចាកចេញពីលំនៅដ្ឋានស្របច្បាប់របស់ខ្លួន និងឆ្លងទៅព្រំដែនវៀតណាមឡើយ"។ កសចស មិនមានយុត្តាធិការស៊ើបអង្កេតលើការនិរទេសរបស់ជនជាតិវៀតណាមក្នុងខេត្តព្រៃវែង ស្វាយរៀង និងក្នុងសហការណ៍ស្រុកត្រាំកក់ឡើយ ដូច្នេះ កថាខណ្ឌក្នុងដីកាដំណោះស្រាយចាប់ពី១៣៩៧ ដល់១៤០១ ត្រូវតែលុបចោល។

១២. ដីកាដំណោះស្រាយលើកឡើងថា "នៅតាមសហការណ៍ និងការដ្ឋានធ្វើការដោយបង្ខំ ដូចនៅពេលផ្លាស់ទីលំនៅប្រជាជនដែរ ខ្មាំងពិត ឬតាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា ត្រូវបានគេធ្វើបាប និងដាក់ឲ្យរស់នៅក្នុងលក្ខណ្ឌដែលពិបាកខ្លាំងជាងប្រជាជនផ្សេងទៀត[28]"។ម្យ៉ាងទៀតដីកាដំណោះស្រាយ បានលើកឡើងថា "ប្រជាជនថ្មី" គឺស្ថិតនៅក្រោមការប្រព្រឹត្តតឹងរឹងជាងប្រជាជនចាស់ក្នុង គោលបំណងលត់ដំ ឬកំណត់អត្តសញ្ញាណ "ខ្មាំង" ក្នុងចំណោមពួកគេ[29]។ ការសន្និដ្ឋានបែបនេះ មិនបានចោទប្រកាន់លើអំពើជាក់លាក់ណាមួយ ឬក៏ការខកខានទប់ស្កាត់ណាមួយដែលនាំឲ្យមានការធ្វើទុក្ខបុកម្នេញ ហើយវាខ្វះភាពច្បាស់លាស់គ្រប់គ្រាន់[30]។ បញ្ហានេះ គឺបណ្តាលមកពី៖

> ដោយសារតែលក្ខណៈមិនច្បាស់លាស់របស់វា ការធ្វើទុក្ខបុកម្នេញ មិនអាចត្រូវបានគេប្រើជាបទចោទប្រកាន់រួមបានទេ។ អនុលោមតាមគោលការណ៍បឋមនៃអំណះអំណាងក្នុងរឿងក្តីព្រហ្មទណ្ឌ

---

[25] *សំណុំរឿងរបស់ អៀង សារី,* ០០២/១៩-០៩-២០០៧-អវតក/កសចស, ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧, ឯកសារលេខ D3, ERN:00141011-00141166, កថាខណ្ឌទី១១, ៤២, ៦៩ ដល់៧០។

[26] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី៤២, ៦៦, ៦៩, ៧២។

[27] កថាខណ្ឌទី៤៣។

[28] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៤១៨។

[29] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១៤១៧។

[30] *រឿងក្តីរដ្ឋអាជ្ញា* តទល់នឹង *Blaškić* , IT-95-14-A, សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ (សាលដីកាលើបណ្តឹងឧទ្ធរណ៍ក្នុងករណី *Blaškić* ) កថាខណ្ឌទី១៣៩ "តុលាការកំពូល កត់សម្គាល់ឃើញថា ព្រះរាជអាជ្ញា ត្រូវចោទប្រកាន់អំពើជាក់លាក់ជាការធ្វើទុកបុកម្នេញ"។ សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Blagojević & Jokić,* IT-02-60-T, សាលក្រម, ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥, កថាខណ្ឌទី៥១៨, *រឿងក្តី រដ្ឋអាជ្ញាតទល់នឹង Brđanin* IT-99-36-T, សាលដីកា, ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ (សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Brđanin)* កថាខណ្ឌ៩៩៤។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Stakić*, IT-97-24-T, សាលដីកា, ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ ( សាលដីការបស់អង្គជំនុំជម្រះលើករណី *Stakić*), កថាខណ្ឌ៧៣៥។

វាមិនគ្រប់គ្រាន់ទេដែលដីកាចោទប្រកាន់ស្ថាពរ បានចោទប្រកាន់ឧក្រិដ្ឋកម្មមួយនៅក្នុងន័យទូលំទូលាយ ។ ដីកាចោទប្រកាន់ស្ថាពរ ត្រូវតែផ្តោតទៅលើអង្គហេតុជាក់លាក់។ ប៉ុន្តែដូចដែលបានកត់សម្គាល់យ៉ាងត្រឹមត្រូវក្នុងយុត្តិសាស្ត្ររបស់តុលាការនេះ ករណីនេះ មិនមែនមានន័យថា ព្រះរាជអាជ្ញា ត្រូវតែធ្វើការចោទប្រកាន់ដាច់ដោយឡែកទាក់ទងនឹងឧក្រិដ្ឋកម្មមូលដ្ឋានទីមួយៗ ដែលបង្កើតបានជាការចោទប្រកាន់ទូទៅនៃការធ្វើទុក្ខបុកម្នេញឡើយ។ អ្វីដែលព្រះរាជអាជ្ញាត្រូវធ្វើ គឺត្រូវបញ្ជាក់លំអិតពីអង្គហេតុសន្សានុម័តនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ប្រឆាំងជនជាប់ចោទ ដែលនៅក្នុងទស្សនៈរបស់ខ្លួន ការចោទប្រកាន់នេះ ទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទ ។ ការខកខានមិនបានធ្វើដូច្នេះ ធ្វើឱ្យដីកាចោទប្រកាន់ស្ថាពរមានលក្ខណៈស្រពិចស្រពិលដែលមិនអាចទទួលយកបាន ព្រោះការខកខានបែបនេះ នឹងប៉ះពាល់ជាអវិជ្ជមានដល់សមត្ថភាពរបស់ជនជាប់ចោទ ក្នុងការរៀបចំការការពារក្តីរបស់គាត់[31]។

១៣. កសចស មិនបានបញ្ជាក់ថាតើ "ប្រជាជនថ្មី" ត្រូវស្ថិតក្រោមការប្រព្រឹត្តខុសគ្នាតាមវិធីណានោះទេ ហើយក៏មិនបានបញ្ជាក់ថាតើស្ថានភាពដែលខ្លាំងពិតប្រាកដ ឬតាមការសន្មត់របស់បក្សកុម្មុយនីស្តកម្ពុជា ស្ថិតនៅក្រោមការប្រព្រឹត្តតឹងរឹងជាងប្រជាជនដទៃទៀតរបៀបណានោះក៏ទេដែរ ។ នៅក្នុងទស្សនៈរបស់ខ្លួន កសចស ខកខានមិនបានបញ្ជាក់ពីអង្គហេតុសត្យានុម័តនៃការប្រព្រឹត្តអំពើឧក្រិដ្ឋរបស់លោក អៀង សារី ដែលក្នុងទស្សនៈរបស់ខ្លួនឧក្រិដ្ឋកម្មនេះទាក់ទងនឹងតួនាទីរបស់គាត់ក្នុងបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយដែលបានចោទប្រកាន់។

១៤. ទាក់ទងនឹង *ធាតុផ្សំអត្តនោម័ត* (*mens rea*) នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា កសចស ខកខានមិនបានបញ្ជាក់ "ថាតើបរិបទនៃការវាយប្រហារ និងកាលៈទេសៈជុំវិញការប្រព្រឹត្តអំពើឧក្រិដ្ឋ បានឆ្លុះបញ្ចាំងពីចេតនាប្រព្រឹត្តរើសអើងដោយសារមូលហេតុសាសនាឡើយ[32]"។ ការសន្និដ្ឋានបែបនេះ មិនបានចោទប្រកាន់អំពើជាក់លាក់ណាមួយ ឬការខកខានណាមិនបានទប់ស្កាត់ ដែលនាំទៅដល់ចេតនាជាក់លាក់ដែលគេតម្រូវដើម្បីបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោយោបាយនោះទេ។ ដូច្នេះវាខ្វះភាពជាក់លាក់គ្រប់គ្រាន់។

១៥. ទាក់ទងនឹង *ធាតុផ្សំអត្តនោម័ត* នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ កសចស មិនបានបញ្ជាក់ថាតើ "បរិបទនៃការវាយប្រហារ និងកាលៈទេសៈជុំវិញការប្រព្រឹត្តអំពើឧក្រិដ្ឋ" បានឆ្លុះបញ្ចាំងពីចេតនា នៃការប្រព្រឹត្តរើសអើងដោយសារមូលហេតុពូជសាសន៍<u>តាមរបៀបណា</u>នោះ

---

[31] *រឿងក្តីរដ្ឋអាជ្ញា* តទល់នឹង *Kupreškić et al*,, IT-95-16-A, សាលក្រម, ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០១, កថាខណ្ឌទី៩៨។

[32] សូមមើលដីកាដំណោះស្រាយ, កថាខណ្ឌទី១៤២៣។

ទេ[33] ។ ការសន្និដ្ឋានបែបនេះ មិនបានចោទប្រកាន់លើការប្រព្រឹត្តអំពើឧក្រិដ្ឋជាក់លាក់ណាមួយ ឬក៏ការខកខានមិនបានទប់ស្កាត់ នាំឲ្យមានចេតនាជាក់លាក់ដែលគេតម្រូវដើម្បីបង្កើតបានជាការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ឡើយ។ ដូច្នេះវាខ្វះភាពជាក់លាក់គ្រប់គ្រាន់។ គ្រប់សេចក្ដីយោង អំពីការធ្វើទុក្ខបុកម្នេញទាំងអស់ក្នុងដីកាដំណោះស្រាយត្រូវតែលុបចោលដោយសារមោឃៈភាពនីតិវិធី។

## ឃ.ការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ

១៦. អង្គជំនុំជម្រះសាលាដំបូងត្រូវតែលុបចោលរាល់ការយោងទាំងអស់ ទាក់ទងនឹងការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើចេញពីដីកាដំណោះស្រាយព្រោះទម្រង់នៃការទទួលខុសត្រូវបែបនេះ មិនត្រូវបានលើកឡើងដោយមានភាពជាក់លាក់គ្រប់គ្រាន់ឡើយ។ យោងតាមអង្គបុរេជំនុំជម្រះក្នុងករណីឌុច "ការចោទប្រកាន់លើការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ មិនត្រឹមតែទាមទារធាតុផ្សំថាអ្វីទៅដែលគេចោទថាជាការប្រព្រឹត្តរបស់ថ្នាក់លើប៉ុណ្ណោះទេ វាថែមទាំងទាមទារថាអ្វីទៅដែលគេចោទប្រកាន់ជាការប្រព្រឹត្តរបស់បុគ្គលដទៃដែលបុគ្គលដែលជាថ្នាក់លើត្រូវទទួលខុសត្រូវ <u>ដោយធ្វើការបញ្ជាក់ឲ្យច្បាស់លាស់តាមដែលអាចធ្វើទៅបាន</u>[34]"។

១៧. យោងតាមយុត្តិសាស្ត្ររបស់តុលាការ ICTR (កាលពីមុន អង្គបុរេជំនុំជម្រះ ធ្លាប់លើកឡើងថាយុត្តិសាស្ត្រនៃតុលាការ *មិនអាចកែប្រែ* ដែលទាក់ទងនឹងទម្រង់នៃការចោទប្រកាន់ គឺមានការពាក់ព័ន្ធក្នុងបរិបទរបស់ អវតក[35])៖

> ប្រសិនបើព្រះរាជអាជ្ញាមានចេតនាពឹកផ្អែកលើទ្រឹស្ដីនៃការទទួលខុសត្រូវ ក្នុងនាមជាថ្នាក់ លើ ដើម្បីឲ្យជនជាប់ចោទទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ចំពោះបទឧក្រិដ្ឋដែលគាត់ប្រព្រឹត្ត ស្របតាមមាត្រា ៦ (៣) នៃលក្ខន្តិកៈរបស់តុលាការ ICTR នោះដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវតែបង្ហាញពីចំណុច៖ (១) ក្នុងស្ថានភាពដែលគាត់មានសមត្ថភាពអាចទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តបទឧក្រិដ្ឋ ជនជាប់ចោទត្រូវតែជាថ្នាក់លើរបស់អ្នកនៅក្រោមបង្គាប់ដែលគេស្គាល់អត្តសញ្ញាណគ្រប់គ្រាន់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ជាក់ស្ដែង និងគាត់ត្រូវដឹងពីសកម្មភាពរបស់ថ្នាក់ក្រោមមួយណាដែលគាត់ត្រូវទទួលខុសត្រូវ (២) ការប្រព្រឹត្តអំពើឧក្រិដ្ឋរបស់អ្នកដទៃដែល

---

33 ដូចជើងទំព័រខាងលើ។

34 សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណី ឌុច, កថាខណ្ឌទី៤៩ (គូសបញ្ជាក់បន្ថែម)។

35 សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌទី៨៣។

ជនជាប់ចោទត្រូវទទួលខុសត្រូវ (៣) ការប្រព្រឹត្តរបស់ជនជាប់ចោទដែលគាត់អាចដឹង ឬមានហេតុផលដែលអាចជឿជាក់បានថានឹងមានការប្រព្រឹត្តអំពើឧក្រិដ្ឋ ឬត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់របស់គាត់ និង(៤) ការប្រព្រឹត្តរបស់ជនជាប់ចោទដែលគេរកឃើញថាគាត់ខកខានក្នុងការបំពេញកាតព្វកិច្ចចាត់វិធានការណ៍សមស្របដើម្បីទប់ស្កាត់ ឬដាក់ទោសចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[36]។

១៨. ដីកាដំណោះស្រាយមិនបានគោរពតាមលក្ខណ្ឌនៃភាពជាក់លាក់។ ដីកានេះ គ្រាន់តែលើកឡើងថា៖

មានភស្តុតាងគ្រប់គ្រាន់ប្រឆាំង **នួន ជា អៀង សារី និង ខៀវ សំផន** ថាជាអ្នកទទួលខុសត្រូវក្នុងនាមជាថ្នាក់លើដោយហេតុផលថា ពួកគេមានអំណាចជាក់ស្តែងលើអ្នកក្រោមបង្គាប់របស់ពួកគេ (កងទ័ពបដិវត្តកម្ពុជា សមាជិកគណៈភូមិភាគ គណៈតំបន់ និងគណៈស្រុក កងឈ្លប និងកម្មាភិបាលមូលដ្ឋាន បុគ្គលិកនៃមន្ទីរសន្តិសុខ ប្រធានកង ឬអ្នកគ្រប់គ្រងការដ្ឋាន និងសហករណ៍ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានរៀបរាប់ដូចខាងក្រោម៖ **ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដោយការធ្វើមនុស្សឃាត** ជាពិសេសអំពើប្រល័យពូជសាសន៍ប្រឆាំង (ក)ជនជាតិចាម (ខ) ជនជាតិវៀតណាម **ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ** ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ជាពិសេស៖ (ក) ការធ្វើមនុស្សឃាតដោយចេតនា (ខ) ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ (គ) ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព (ឃ) ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀតទាត់ (ង) ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ (ច) ការនិរទេសជនស៊ីវិលដោយខុសច្បាប់ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** ជាពិសេស (ក) ការធ្វើមនុស្សឃាត (ខ)ការម្លាប់រង្គាល (គ)ការធ្វើឱ្យទៅជាទាសករ (ឃ)ការនិរទេស (ង)ការដាក់ក្នុងមន្ទីរឃុំឃាំង (ច)ការធ្វើទារុណកម្ម (ឆ)ការរំលោភលើផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ជ)ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ (ឈ)ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍លើជនជាតិវៀតណាម (ញ) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាលើជនជាតិចាម (ដ)ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាលើពុទ្ធសាសនិក (ឋ) អំពើអមនុស្សធម៌ផ្សេងទៀត (ក្រោមទម្រង់ជាការប៉ះពាល់ដល់ការថ្លៃថ្នូរជាមនុស្ស ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)។ លោក **នួន ជា អៀង សារី និង ខៀវ សំផន** បានដឹង ឬមានហេតុផលដែល អាចដឹងថានឹងមានការប្រព្រឹត្តបទល្មើស

[36] *រឿងក្តីរដ្ឋអាជ្ញា* តទល់នឹង Muyunyi, ICTR-2000-55A-A, សាលដីកា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨, កថាខណ្ឌទី១៩ (គូសបញ្ជាក់បន្ថែម)។

ដូចខាងលើពីសំណាក់ថ្នាក់ក្រោមខ្លួន ហើយពួកគេខកខានក្នុងការបំពេញកាតព្វកិច្ចចាត់វិធានការចាំបាច់ដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះ។ ម្យ៉ាងវិញទៀត **នួន ជា អៀង សារី និង ខៀវ សំផន** បានដឹង ឬមានហេតុផលដែលអាចដឹងថា នឹងមានការប្រព្រឹត្តបទល្មើសដូចខាងលើពីសំណាក់ថ្នាក់ក្រោមខ្លួនហើយពួកគេ ខកខានក្នុងការបំពេញកាតព្វកិច្ចផ្តន្ទាទោសចារីដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[37]។

១៩. ការសន្និដ្ឋាននេះ មិនបានបញ្ជាក់ពីលក្ខណៈជាក់លាក់អ្វីទាំងអស់ទាក់ទងនឹង (ក) ការប្រព្រឹត្តរបស់លោក អៀង សារី (ខ) នរណាខ្លះជាអ្នកនៅក្រោមបង្គាប់របស់គាត់ (គ) លក្ខណៈនៃទំនាក់ទំនងថ្នាក់លើ/អ្នកនៅក្រោមបង្គាប់ (ឃ) ភស្តុតាងដែលថាលោក អៀង សារី មានកាតព្វកិច្ចស្របច្បាប់ដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មអ្នកនៅក្រោមបង្គាប់របស់គាត់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម (ង) អ្វីទៅជាបទឧក្រិដ្ឋជាក់លាក់ដែលអ្នកនៅក្រោមបង្គាប់របស់លោកបានប្រព្រឹត្ត ដែលបណ្តាលឲ្យមានអំពើប្រល័យពូជសាសន៍ ការរំលោភយ៉ាងធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ច) ភស្តុតាងអ្វីខ្លះដែលគាំទ្រការដឹងឮរបស់លោក អៀង សារី អំពីឧក្រិដ្ឋកម្មដែលអ្នកនៅក្រោមបង្គាប់របស់គាត់បានប្រព្រឹត្ត ឬ (ឆ) ភស្តុតាងអ្វីខ្លះដែលគាំទ្រការអះអាងដែលថា លោក អៀង សារី ខកខានមិនបានទប់ស្កាត់ឧក្រិដ្ឋកម្មទាំងនេះ ឬផ្តន្ទាទោសចារីដែលបានប្រព្រឹត្ត។ ការអះអាងនៅក្នុងដីកាដំណោះស្រាយ គឺមិនមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ដើម្បីផ្តល់ការកត់សម្គាល់សមស្របដល់លោក អៀង សារី អំពីវិធីសាស្ត្រដែលការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើនឹងត្រូវបានគេយកទៅអនុវត្តក្នុងរឿងក្តីរបស់គាត់ឡើយ។ ដោយសារតែដីកាដំណោះស្រាយ ខកខានមិនបានបញ្ជាក់ពីអំពើឧក្រិដ្ឋជាក់លាក់ ឬដំណើរនៃការប្រព្រឹត្តជាក់លាក់ដែលនឹងគាំទ្រដល់ការអនុវត្តទម្រង់នៃការទទួលខុសត្រូវបែបនេះ រាល់ការយោងទាំងអស់ទាក់ទងនឹងការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើនៅក្នុងដីកាដំណោះស្រាយ ត្រូវតែលុបចោលដោយសារមោឃៈភាពនីតិវិធី។

**ខ.សហឧក្រិដ្ឋកម្មរួម**

២០. អង្គជំនុំជម្រះសាលាដំបូងត្រូវតែលុបចោលរាល់ការយោងទាំងអស់ទាក់ទងនឹង សហឧក្រិដ្ឋកម្មរួមចេញពីដីកាដំណោះស្រាយព្រោះ កសចស (ក) បានអនុវត្តដោយខុសឆ្គងនូវ *ធាតុផ្សំអត្តនោម័ត* (*mens rea*) ទាក់ទងនឹងការចូលរួមរបស់លោក អៀង សារី ក្នុងផែនការឧក្រិដ្ឋកម្មរួម និង (ខ) កសចស បានលើកឡើងដោយមានកំហុសឆ្គងថា ផែនការឧក្រិដ្ឋកម្មរួម បានពន្លាតដើម្បីដាក់

---

[37] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៥៩ ដល់១៥៦០។

បញ្ចូលអំពើប្រល័យពូជសាសន៍ដែលមិនបានបង្ហាញពីចេតនាច្បាស់លាស់។

២១. យោងតាមអង្គបុរេជំនុំជម្រះ "JCE ទម្រង់មូលដ្ឋាន (JCE I) កើតមាននៅពេលដែល អ្នកចូលរួមទាំងឡាយ បានប្រព្រឹត្តដោយផ្អែកលើមូលដ្ឋាននៃគ្រោងការណ៍រួម ឬសហគ្រាសរួម ហើយមានចេតនាដូចគ្នាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម[38]"។ ដីកាដំណោះស្រាយខកខានមិនបានបង្ហាញថា លោក អៀង សារី បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដោយមានចេតនារួមគ្នាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អវតក ឡើយ ហើយដីកានេះ ហាក់បីដូចជាបានអនុវត្តខុសនូវ JCE ដោយផ្អែកលើការយល់ខុសអំពីបំណងឧក្រិដ្ឋជាក់លាក់ទាក់ទងនឹង JCE ទម្រង់មូលដ្ឋាន (JCE I)។ ដីកាដំណោះស្រាយលើកឡើងថា៖

> ផែនការរួមរបស់បក្សកុម្មុយនីស្តកម្ពុជា គឺធ្វើឱ្យសម្រេចបាននូវបដិវត្តន៍សង្គមនិយមឆាប់រហ័សនៅកម្ពុជា តាមរយៈ "ជំហានមហាលោតផ្លោះ" និងការការពារប្រទេសប្រឆាំងទាំងសត្រូវខាងក្នុង និងខាងក្រៅ តាមគ្រប់មធ្យោបាយចាំបាច់។ ផែនការរួមនេះពុំមានលក្ខណៈឧក្រិដ្ឋទាំងស្រុងនោះទេ ប៉ុន្តែការធ្វើឱ្យសម្រេចផែនការរួមនេះ រួមមានជាការប្រព្រឹត្តនូវឧក្រិដ្ឋកម្មដែលស្ថិតក្នុងយុត្តាធិការរបស់ អវតក ឬជាការពាក់ព័ន្ធទៅនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។ ដើម្បីសម្រេចផែនការរួមនេះ មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា បានកំណត់យកគោលនយោបាយប្រាំយ៉ាងដូចមានរៀបរាប់ខាងក្រោមដែលការដាក់ឱ្យអនុវត្តនូវគោលនយោបាយនេះ ដែលការអនុវត្តរួមមានការប្រព្រឹត្តនូវឧក្រិដ្ឋកម្ម ឬជាការជាប់ពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មដោយសមាជិករបស់សហឧក្រិដ្ឋ-កម្មរួម ព្រមទាំងបុគ្គលនានាដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនេះ...[39]។

២២. ដីកាដំណោះស្រាយនេះហាក់បីដូចជាទទួលស្គាល់ថាគោលបំណងរួមអាចថាពុំមានលក្ខណៈឧក្រិដ្ឋ និងថាគោលបំណងរួមនេះអាចនឹងមិនមានចេតនាដាក់ឱ្យគេអនុវត្តតាមគោលនយោបាយដែលមានលក្ខណៈឧក្រិដ្ឋ ប៉ុន្តែមានតែលទ្ធផលនៃការអនុវត្តគោលនយោបាយនេះតែប៉ុណ្ណោះ ដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋ។ ដីកាដំណោះស្រាយលើកឡើងថា៖ "ចេតនាឧក្រិដ្ឋ របស់លោក អៀង សារី អាចទាញសេចក្ដីសន្និដ្ឋានចេញពីពាក្យសំដី សកម្មភាពសកម្ម ឬសកម្មភាពអកម្មរបស់គាត់[40]"។ ប៉ុន្តែ "JCE ទម្រង់I កើតមាននៅពេលដែលគោលបំណងរួម បណ្ដាលឱ្យមាន ឬពាក់ព័ន្ធទៅនឹងការប្រព្រឹត្តិបទឧក្រិដ្ឋដែលមានចែងនៅក្នុងលក្ខន្តិកៈ ។ *ធាតុផ្សំអត្តនោម័ត* នៃ JCE ទម្រង់I

---

[38] សាលដីការបស់ អបជ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌ៣៧ (គូសបញ្ជាក់បន្ថែម)។

[39] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥២៤ ដល់១៥២៥ (គូសបញ្ជាក់បន្ថែម)។

[40] ដូចដើងទំព័រខាងលើ, កថាខណ្ឌទី១៥៣៥។

គឺថាអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមដែលរួមបញ្ចូលទាំងជនជាប់ចោទផងនោះ មានគំនិតដូចគ្នាពោលគឺគំនិតថាឧក្រិដ្ឋកម្ម ដែលកំណត់ដោយលក្ខន្តិកៈដែលបង្កើតបានជាគោលបំណងរួមនេះត្រូវតែបានគេអនុវត្ត[41]"។ អត្ថិភាពនៃផែនការរួម ដែលគ្រាន់តែបណ្តាលឲ្យមានការប្រព្រឹត្តិបទឧក្រិដ្ឋ គឺមិនស៊ីសង្វាក់គ្នាទៅនឹងលក្ខណ្ឌតម្រូវដែលថាលោក អៀង សារី ត្រូវតែចូលរួមក្នុងផែនការរួម ដែលមានចេតនារួមក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការរបស់ អវតក[42]។ ការអះអាងថា លោក អៀង សារី មានចេតនាធ្វើឲ្យមានលទ្ធផលឧក្រិដ្ឋ ជាពិសេសដោយមិនបានផ្តល់នូវភស្តុតាងអំពីចេតនារបស់គាត់ គឺមិនទាន់គ្រប់គ្រាន់ ដើម្បីគាំទ្រភស្តុតាងបឋម នៃ JCE ទម្រង់I[43]។

២៣. ការសន្និដ្ឋានក្នុងដីកាដំណោះស្រាយដែលថា JCE អាចកើតមានឡើងនៅពេលដែលឧក្រិដ្ឋកម្មគ្រាន់តែជា លទ្ធផលដែលបណ្តាលមកពីគោលនយោបាយមិនមានលក្ខណៈឧក្រិដ្ឋដែលគេប្រើដើម្បីសម្រេចបាននូវផែនការរួមដែលមិនមានលក្ខណៈឧក្រិដ្ឋ គឺប្រាសចាកទៅនឹងយុត្តិសាស្ត្រដែលបានបង្កើតឡើងនៅក្នុងតុលាការ *មិនអចិន្ត្រៃយ៍* ។ បទដ្ឋានបែបនេះ ហាក់បីដូចជាមានលក្ខណៈទាបជាងបទដ្ឋាននៅតុលាការSCSLដែលរងការរិះគន់យ៉ាងធ្ងន់ធ្ងរទៅទៀត[44]។ បទដ្ឋានដែលរងការ

---

[41] រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Krajišnik*,, IT-00-39-T, សាលក្រម, ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៦, កថាខណ្ឌ ៨៨៣។ សូមមើលផងដែរ រឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Brđanin*, IT-99-36-A, សាលដីកា ,ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ (សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Brđanin)*, កថាខណ្ឌទី៤១៨៖ "ក្នុងរឿងក្តីណាក៏ដោយ អ្វីដែល JCE តម្រូវ គឺអត្ថិភាពនៃគោលបំណងរួម ដែលនាំទៅដល់ ឬទាក់ទងនឹងការប្រព្រឹត្តបទឧក្រិដ្ឋ... ទាក់ទងនឹងទម្រង់មូលដ្ឋានរបស់ JCE លក្ខខណ្ឌចំបាច់ដើម្បីដាក់ទោសសមាជិកជនជាប់ចោទណាមួយនៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តដោយបុគ្គលដទៃទៀត គឺថាបទល្មើសដែលពាក់ព័ន្ធ *បង្កើតបានជាគោលបំណងឧក្រិដ្ឋកម្មរួម*'។ (គូសបញ្ជាក់បន្ថែម, គូសបញ្ជាក់ដោយមានបន្ទាត់ទ្រេត)។ សូមមើលផងដែរសាលដីកាសម្រេចរបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌទី៣៨។

[42] សូមមើលសាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសហឧក្រិដ្ឋកម្មរួម, កថាខណ្ឌទី៣៩៖ "JCE ទម្រង់ I តម្រូវឲ្យមានចេតនារួមដើម្បីប្រព្រឹត្តបទឧក្រិដ្ឋ"។

[43] គឺជាភស្តុតាងដែលគួរឲ្យជឿជាក់ដែល (ប្រសិនបើមិនត្រូវបានជំទាស់ដោយមេធាវីការពារក្តីទេនោះ) នឹងក្លាយជាមូលដ្ឋានគ្រប់គ្រាន់មួយដើម្បីវិនិច្ឆ័យលើ ជនត្រូវចោទលើបទចោទប្រកាន់ដែលមាន។ ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៥ *ដោយដកស្រង់* រឿងក្តី *Kordic et atl,* ការពិនិត្យលើដីកាចោទប្រកាន់ ឆ្នាំ ១៩៩៥ (គ្មានលេខទំព័រ ឬលេខកថាខណ្ឌ ឬថ្ងៃខែដាក់លាក់ ឬលេខសំគាល់រឿងក្តីត្រូវបានគេផ្តល់ឡើយ) (គូសបញ្ជាក់បន្ថែម)។

[44] សូមមើលឧទាហរណ៍ អត្ថបទរបស់ Wayne Jordash និង Penelope Van Tuyl, ការខកខានមិនបានអនុវត្តបន្ទុកនៃភស្តុតាង ៖ តើសហឧក្រិដ្ឋកម្មរួមមិនត្រូវបានគេយកទៅអនុវត្តនៅ តុលាការពិសេសសម្រាប់សេរ៉ាឡេអូន តាមរបៀបណា, 8 J. INT'L CRIME. JUST. 519 (2010) ។ អត្ថបទរបស់ Cecily Rose, ដីកាចោទប្រកាន់ដែលមានបញ្ហានៅតុលាការពិសេស

រិះគន់នោះ លើកឡើងថាដើម្បីសម្រេចគោលបំណងមួយ ផែនការឧក្រិដ្ឋកម្ម ត្រូវតែជាការគិតទុកឲ្យបានម៉ត់ចត់អំពីការប្រព្រឹត្តិឧក្រិដ្ឋកម្មដែលស្ថិតក្នុងលក្ខន្តិកៈរបស់តុលាការ SCSL[45]។ ដូចដែលបានសង្កេតដោយចៅក្រម Fisher នៅក្នុងទស្សនៈជំទាស់មួយផ្នែករបស់គាត់ក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍ក្នុងរឿងក្ដី *Sesay et al* "ចាប់តាំងពីបានបង្កើតឡើងដោយអង្គជំនុំជម្រះតុលាការកំពូល ICTY ក្នុងរឿងក្ដី *Tadić* ទ្រឹស្ដី JCE" ទទួលរងនូវការរិះគន់ដោយសារតែការអនុវត្តហួសព្រំដែន។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវតែពិចារណាឲ្យបានម៉ត់ចត់អំពីការព្រមាននេះ ហើយធានាឲ្យបានថាធាតុផ្សំផ្នែកច្បាប់នៃJCE ដែលមានការបកស្រាយយ៉ាងម៉ត់ចត់ ត្រូវបានគេយកមកអនុវត្តយ៉ាងស៊ីសង្វាក់គ្នាដើម្បីប្រឆាំងទៅនឹង JCE ដែលកំពុងត្រូវបានគេយកទៅអនុវត្តហួសព្រំដែន[46]។

២៤. ប្រសិនបើតាមរយៈការទាញសេចក្ដីសន្និដ្ឋានរបស់ខ្លួន កសចស យល់ឃើញថាលោក អៀង សារី ពិតជាបានចូលរួមក្នុងផែនការឧក្រិដ្ឋកម្មរួមដែលមានចេតនារួមដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មដែលនេះមិនមែនគ្រាន់តែជាការទាញសេចក្ដីសន្និដ្ឋាន ដែលសមហេតុផលតែមួយគត់ដែលគេត្រូវធ្វើឡើងផងនោះ[47] កសចស ត្រូវតែបង្ហាញ "អង្គហេតុ និងកាលៈទេសៈដែលនាំទៅដល់ការទាញសេចក្ដីសន្និដ្ឋានរបស់ខ្លួន[48]"។ ប៉ុន្តែ កសចស មិនបានធ្វើដូច្នេះឡើយ។ អង្គហេតុ និងកាលៈទេសៈដែល កសចស បានលើកឡើងទាក់ទងនឹងការចូលរួម ឬការរួមចំណែករបស់លោក អៀង សារី ក្នុងផែនការរួម មិនបានគាំទ្រដល់ការទាញសេចក្ដីសន្និដ្ឋានដែលថាលោក អៀង សារី មានចេតនាប្រព្រឹត្តអំពើឧក្រិដ្ឋ[49]ឡើយ។ អង្គហេតុ និងកាលៈទេសៈទាំងនោះ គ្រាន់តែបានគាំទ្រដល់ការទាញសេចក្ដីសន្និដ្ឋានដែលថាលោក អៀង សារី មានចេតនាចូលរួមក្នុងផែនការមួយដែលមិនមានលក្ខណៈឧក្រិដ្ឋជាប់មកជាមួយ និងដែលគេមានបំណងសម្រេចតាមរយៈគោលនយោបាយដែលពុំមាន

---

សម្រាប់សេរ៉ាឡេអូន, សេចក្ដីសន្និដ្ឋានអំពីសហឧក្រិដ្ឋកម្មរួម និងឧក្រិដ្ឋកម្មទាក់ទងនឹងផ្លូវភេទ 7(2) INT'L CRIME. JUST. 353 (2009)។

45 *រឿងក្ដីរដ្ឋអាជ្ញា* តទល់នឹង *Brima et al*…, SCSL-2004-16-A, សាលដីកា, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨, កថាខណ្ឌទី៧៦។

46 *រឿងក្ដីរដ្ឋអាជ្ញា* តទល់នឹង Sesay et al. SCSL-04-15-A, សាលដីកា, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩, យោបល់ជំទាស់ និងយោបល់ស្របរបស់ចៅក្រមជាន់ខ្ពស់ Shireen Avis Fisher, កថាខណ្ឌទី៥៤។

47 សាលដីកាលើបណ្ដឹងឧទ្ធរណ៍ *Brdanin*, កថាខណ្ឌទី៤២៨។

48 *រឿងក្ដីរដ្ឋអាជ្ញា* តទល់នឹង Kronojelac, IT-97-25-T, សេចក្ដីសម្រេចលើទម្រង់នៃដីកាចោទប្រកាន់ទី២ដែល បានធ្វើការកែប្រែ, ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០០, កថាខណ្ឌទី១៦។

49 សូមមើលដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៣៤។

លក្ខណៈឧក្រិដ្ឋជាប់មកជាមួយ ។

២៥. ម្យ៉ាងវិញទៀត នៅពេលដែលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងអំពើប្រល័យពូជសាសន៍ តម្រូវឲ្យមានចេតនាជាក់លាក់ នោះដីកាដំណោះស្រាយក៏ត្រូវបញ្ជាក់ពីអង្គហេតុ និងកាលៈទេសៈដែលនាំឲ្យ កសចស សន្និដ្ឋានថា លោក អៀង សារី ពិតជាមានចេតនាជាក់លាក់បែបនេះមែន។ ដូចដែលបានពន្យល់ដោយតុលាការ ICTY ក្នុងរឿងក្តី *Kvočka* និងដូចដែលបានគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូល "ក្នុងករណីដែលបទឧក្រិដ្ឋតម្រូវឲ្យមានចេតនាពិសេស...ជនជាប់ចោទត្រូវតែបំពេញតាមលក្ខណ្ឌបន្ថែមដែលដាក់ដោយឧក្រិដ្ឋកម្មនោះ ដូចជាចេតនារើសអើងដោយមូលហេតុនយោបាយ ពូជសាសន៍ ឬក៏មូលហេតុសាសនា ប្រសិនបើគាត់ជាសហចារី[50]"។ កសចស មិនបានពន្យល់តើអ្វីជាភស្តុតាងដែលខ្លួនរកឃើញដើម្បីគាំទ្រចេតនារបស់លោក អៀង សារី ឡើយ។ ដូច្នេះរាល់កថាខណ្ឌទាំងអស់ដែលលើកឡើងអំពី JCE ត្រូវតែលុបចេញពីដីកាដំណោះស្រាយ។

២៦. ប្រសិនជា អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាការយោងអំពី JCE មិនត្រូវលុបចេញពីដីកាដំណោះស្រាយទេនោះ ជម្រើសមួយទៀត គឺរាល់ការយោងទាំងអស់អំពី JCE ដែលពន្លាតដល់ការដាក់បញ្ចូលអំពើប្រល័យពូជសាសន៍ ត្រូវតែលុបចេញ។ ដីកាដំណោះស្រាយ បានលើកឡើងថា៖

> ទាក់ទងនឹងគោលនយោបាយប្រឆាំងជនជាតិចាម និងជនជាតិវៀតណាម ផែនការកម្ទេចក្រុមមនុស្សទាំងអស់នេះ បានកើតឡើងចាប់តាំងពីខែមេសា ឆ្នាំ ១៩៧៧ ចំពោះជនជាតិវៀតណាម និងចាប់តាំងពីដើមឆ្នាំ១៩៧៧ ចំពោះជនជាតិចាម។ បន្ទាប់ពីនោះមក សមាជិកសហឧក្រិដ្ឋរួម <u>បានដឹង</u>អំពីការដែលថា ការធ្វើឲ្យបានសម្រេចនូវផែនការរួមត្រូវបានពន្លាតផងដែរដល់ការប្រព្រឹត្តិប្រល័យពូជសាសន៍ទៅលើក្រុមមនុស្សដែលទទួលបានការការពារទាំងនោះ ។ ការដែលថា សមាជិកសហឧក្រិដ្ឋកម្មរួម <u>ទទួលយក</u>ការបង្កើនមធ្យោបាយប្រព្រឹត្តឧក្រិដ្ឋកម្មដែលមធ្យោបាយនេះត្រូវបានប្រើប្រាស់ដើម្បី<u>ធ្វើឲ្យបានសម្រេច</u>នូវផែនការរួម មានន័យថាសមាជិកទាំងនោះមាន<u>ចេតនា</u>ក្នុងការធ្វើឲ្យបានសម្រេចនូវផែនការនោះតាមរយៈអំពើប្រល័យពូជសាសន៍[51]។

២៧. យុត្តិសាស្ត្ររបស់តុលាការ ICTY អនុញ្ញាតឲ្យមានភវនីយភាពដែលថាផែនការឧក្រិដ្ឋកម្មរួមទាក់នឹង JCE អាចពន្លាត ហើយការទទួលយកការពន្លាតដោយសមាជិកសហឧក្រិដ្ឋកម្មរួម អាចត្រូវ

---

[50] *រឿងក្តីវដ្តអាជ្ញា* តទល់នឹង *Kvočka et al.*,,IT-98-30/1-A, សាលដីកា, ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Kvocka*" ), កថាខណ្ឌទី១០៩ដល់ ១១០។

[51] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥២៧ (គូសបញ្ជាក់បន្ថែម)។

បានសម្រេចដោយការទាញសេចក្តីសន្និដ្ឋាន[52]។ បញ្ហាដែលទាក់ទងនឹងការលើកឡើងបែបនេះនៅក្នុងដីកាដំណោះស្រាយ គឺផ្អែកលើអង្គហេតុដែលថាអំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មដោយមានចេតនាជាក់លាក់។ ដូច្នេះ ការដឹងឮ ឬការទទួលយកអំពើប្រល័យពូជសាសន៍ មិនមែនជាចេតនាជាក់លាក់ដើម្បីកម្ទេចទាំងស្រុង ឬជាផ្នែកនូវក្រុមមនុស្សឡើយ។ ចំណុចនេះត្រូវបានពន្យល់ដោយអង្គជំនុំជម្រះតុលាការកំពូល ICTY ក្នុងរឿងក្តី *Krstić* ។ អង្គជំនុំជម្រះតុលាការកំពូល បានរកឃើញថា៖

> ភស្តុតាងដែលអាចរកបាន គឺថា *Krstić* <u>បានដឹង</u>ពីចេតនាប្រព្រឹត្តិអំពើប្រល័យពូជសាសន៍របស់សមាជិកមួយចំនួននៃ VRS Main Staff បន្ទាប់ពីបានដឹងពីបញ្ហានេះ គាត់មិនបានចាត់វិធានការណ៍អ្វីទាំងអស់ដើម្បីទប់ស្កាត់ការប្រើប្រាស់កងកម្លាំងយោធា Drina Corps និងធនធានដទៃទៀតដើម្បីជាជំនួយដល់ការសម្លាប់ទាំងនោះ។ <u>ការដឹងឮតែខ្លួនគាត់ម្នាក់ ឯងមិនអាចគាំទ្រការទាញសេចក្តីសន្និដ្ឋានអំពីចេតនាប្រព្រឹត្តិអំពើប្រល័យពូជសាសន៍បានឡើយ។ អំពើប្រល័យពូជសាសន៍ គឺជាទម្រង់មួយក្នុងចំណោមទម្រង់ឧក្រិដ្ឋដ៏អាក្រក់បំផុតប្រឆាំងមនុស្សលោក ហើយស្ថានទំងន់របស់វាត្រូវបានឆ្លុះបញ្ចាំងក្នុងលក្ខណ្ឌម៉ត់ចត់នៃចេតនាជាក់លាក់</u> ។ ការផ្តន្ទាទោសពីបទប្រល័យពូជសាសន៍ អាចត្រូវបានធ្វើឡើងតែក្នុងករណីដែលចេតនានៃការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍នោះ ត្រូវបានគេរកឃើញដោយគ្មានមន្ទិលសង្ស័យតែប៉ុណ្ណោះ[53]។

២៨. នេះមិនមែនជាបញ្ហាទាក់ទងនឹងភស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រការទាញសេចក្តីសន្និដ្ឋានអំពីចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ។ បញ្ហាវាស្ថិតនៅលើការដែលថា កសចស បានសន្និដ្ឋានដោយខុសឆ្គងថាចេតនាជាក់លាក់ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដោយអ្នកចូលរួម JCE ទម្រង់I អាចត្រូវបានទាញចេញពីការដឹងឮអំពីការពន្លាតសហឧក្រិដ្ឋកម្មរួម និងការទទួលយកការដឹងឮនោះតែប៉ុណ្ណោះ។ វាមិនអាចទៅរួចទេ។ ដូច្នេះរាល់សេចក្តីយោងទាំងអស់ទាក់ទងនឹងផែនការឧក្រិដ្ឋកម្មរួម ត្រូវតែលុបចោលពីដីកាដំណោះស្រាយ។

### ច. ការធ្វើផែនការរួម ការញុះញុង ការជួញ និងជំរុញ និងការបញ្ជា

២៩. អង្គជំនុំជម្រះសាលាដំបូងត្រូវតែលុបចោលរាល់ការយោងទាំងអស់ទាក់ទង នឹងការធ្វើផែនការរួម ការញុះញុង ការជួញ និងជំរុញ ព្រោះដីកាដំណោះស្រាយខកខានមិនបានបញ្ជាក់ពីប្រភេទបទល្មើសជាក់លាក់អំពីអង្គហេតុដើម្បីគាំទ្រទម្រង់នៃការទទួលខុសត្រូវនេះឡើយ។ យោងតាមអង្គបុរេជំនុំ

[52] រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Krajišnik* IT-00-39-A, សាលដីកា, ថ្ងៃទី១៧ ខែមិនា ឆ្នាំ២០០៩, កថាខណ្ឌទី១៦៣។

[53] សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Krstić*, កថាខណ្ឌទី១៣៤ (គូសបញ្ជាក់បន្ថែម)។

ជម្រះ "ក្នុងករណីមានការចោទប្រកាន់ថាជនជាប់ចោទបានរៀបចំផែនការ ញុះញង់ បង្គាប់បញ្ជាឬ ជួយ និងទំនុកបម្រុងនៅក្នុងការប្រព្រឹត្តបទល្មើសដែលចោទប្រកាន់ "អំពើជាក់លាក់" ឬ "ការប្រ-ព្រឹត្តជាក់លាក់" របស់ជនជាប់ចោទ ដែលបង្កើតជាសំអាងនៃបទចោទដែលមានភាពចម្រូង ចម្រាសនេះ ត្រូវតែបង្ហាញចេញ[54]"។ កសចស មិនបានធ្វើដូច្នេះឡើយ ប៉ុន្តែគ្រាន់តែបានលើកឡើង ក្នុងផ្នែកពាក់ព័ន្ធនៅចំណងអត្ថបទ "ការកំណត់ប្រភេទទម្រង់នៃការទទួលខុសត្រូវ" ថា៖

> ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថាមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី** និង **ខៀវ សំផន** ថាបានរៀបចំផែនការប្រព្រឹត្តឧក្រិដ្ឋកម្មដូចខាងក្រោមនេះ៖
>
> ......
>
> ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថាមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី** និង **ខៀវ សំផន** ថាបានញុះញង់អ្នកដទៃទៀតឱ្យប្រព្រឹត្តឧក្រិដ្ឋកម្មដូចខាងក្រោមនេះ៖
>
> .......
>
> ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថាមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី** និង **ខៀវ សំផន** ថាបានសមគំនិតតាមការជួយ និងជម្រុញដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានរៀបរាប់ខាងក្រោមនេះ[55]៖
>
> .........
>
> ផ្អែកលើមូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" នៃដីកាដំណោះស្រាយនេះ ការស៊ើបសួរបង្ហាញថាមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹង **នួន ជា អៀង សារី** និង **ខៀវ សំផន** ថាបានចេញបញ្ជាដល់អ្នកក្រោមបង្គាប់របស់ខ្លួន (កងទ័ពបដិវត្តកម្ពុជា សមាជិកគណៈភូមិភាគ គណៈតំបន់ និងគណៈស្រុក កងឈ្លបនិងកម្មាភិបាលមូលដ្ឋាន បុគ្គលិកនៃមន្ទីរសន្តិសុខ ប្រធានកង ឬអ្នកគ្រប់គ្រងការដ្ឋាន និងសហករណ៍) ដែលទង្វើនេះបានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានរៀបរាប់ដូចខាងក្រោមនេះ។

៣០. អំពើជាក់លាក់ ឬដំណើរការជាក់លាក់នៃការប្រព្រឹត្តដែលបំពេញទម្រង់ផ្សេងៗគ្នានីមួយៗនៃការ

---

[54] សាលដីការបស់ អបជ លើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំបញ្ជូនរឿងទៅជំនុំជម្រះក្នុងករណី ឌុច កថាខណ្ឌ ៤៩ (គូសបញ្ជាក់បន្ថែម) ។

[55] ដីកាដំណោះស្រាយ, កថាខណ្ឌទី១៥៤៥, ១៥៤៨, ១៥៥១, ១៥៥៤។

ទទួលខុសត្រូវដែលគេយកមកអនុវត្ត មិនត្រូវបានចោទប្រកាន់ឡើយ ។ មូលដ្ឋាននៃភស្តុតាងដែលបានរៀបរាប់នៅក្នុងផ្នែកស្តីពី "ជនត្រូវចោទ" ក្នុងដីកាដំណោះស្រាយ មិនបានពន្យល់ឲ្យច្បាស់ថាតើទម្រង់នៃការទទួលខុសត្រូវនេះ ត្រូវយកមកអនុវត្តតាមរបៀបណានោះទេ។ ឧទាហរណ៍ ដីកាដំណោះស្រាយមិនបានពន្យល់ពីវិធីដែលលោក អៀង សារី បានអនុវត្តនូវលក្ខខណ្ឌបញ្ជាឡើយ៖"ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌពីបទចេញបទបញ្ជា កើតឡើងនៅពេលដែលបុគ្គលដែលមានអំណាច បានផ្តល់ ឬបញ្ជូនដោយប្រយោល ឬយ៉ាងជាក់លាក់នូវបទបញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មដោយមានគោលបំណង ឬការដឹងឮអំពីភវនីយភាពដែលថានឹងមានការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងពេលអនុវត្តបទបញ្ជានោះ[56]"។ ដីកាដំណោះស្រាយក៏មិនធ្លាប់អះអាងថាលោក អៀង សារី ញុះញង់ឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែរ។ ដោយសារតែដីកាដំណោះស្រាយខកខានមិនបានលើកឡើងពីអំពើជាក់លាក់ ឬដំណើរការជាក់លាក់នៃការប្រព្រឹត្តដែលនឹងគាំទ្រដល់ការអនុវត្តផែនការញុះញង់ ជួយ និង ជម្រុញ ឬក៏បញ្ជាឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ផ្នែកខ្លះក្នុងដីកាដំណោះស្រាយដែលអនុវត្តនូវទម្រង់នៃការទទួលខុសត្រូវបែបនេះ ត្រូវតែលុបចោលដោយសារមោឃៈភាពនីតិវិធី។

៣១. ជាងនេះទៅទៀត ទម្រង់នៃការទទួលខុសត្រូវទាំងនេះ ត្រូវតែលុបចេញពីដីកាដំណោះស្រាយ ព្រោះបន្ទាប់ពីពិភាក្សាពី JCE ដីកាដំណោះស្រាយលើកឡើងថា៖ "ដោយបន្ថែម ឬដោយឆ្លាស់គ្នា ទម្រង់មួយឬទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលមានរៀបរាប់នៅក្រោមនេះ (រៀបចំផែនការ ញុះញង់ បញ្ជា ជួយ និងជម្រុញ) ក៏អនុវត្តចំពោះអង្គហេតុនៃរឿងក្តីនេះផងដែរ[57]"។ វាមិនត្រឹមត្រូវទេការដែលលើកឡើងថាទម្រង់នៃការទទួលខុសត្រូវទាំងនេះ អាចត្រូវបានគេយកមកអនុវត្តបន្ថែមលើការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម។ បុគ្គលម្នាក់អាចមិនត្រូវបានទទួលខុសត្រូវចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម និងការរៀបចំផែនការឧក្រិដ្ឋកម្មដូចគ្នាឡើយ។ "ក្នុងករណីដែលជនជាប់ចោទត្រូវបានគេរកឃើញថាមានពិរុទ្ធពីបទប្រព្រឹត្តឧក្រិដ្ឋកម្ម នៅពេលជាមួយគ្នានោះគាត់/នាង មិនអាចត្រូវបានផ្តន្ទាទោសពីបទរៀបចំផែនការឧក្រិដ្ឋកម្មដូចគ្នាឡើយ"។ ប៉ុន្តែការជាប់ពាក់ព័ន្ធនឹងការរៀបចំផែនការប្រព្រឹត្តឧក្រិដ្ឋកម្ម អាចត្រូវបានគេចាត់ទុកថាជាកត្តាដែលធ្វើឲ្យបញ្ហា

[56] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១៥៥៣។

[57] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១៥៤២ (គូសបញ្ជាក់បន្ថែម)។

កាន់តែធ្ងន់ធ្ងរទៅៗ[58]។ ដូច្នេះ ការញុះញង់[59] បញ្ជា[60] និងការជួយ និងជម្រុញ[61] ក៏ជាកត្តា១ បែបនេះដែរ។ ប្រសិនបើ កសចស ចង់លើកឡើងថាលោក អៀង សារី បានប្រព្រឹត្តឧក្រិដ្ឋកម្មមួយចំនួន ឬឧក្រិដ្ឋកម្មច្រើន នៅពេលដែលគាត់គ្រាន់តែបានរៀបចំផែនការ ញុះញង់ បញ្ជា ឬ ជួយ និងជម្រុញឲ្យប្រព្រឹត្តបទឧក្រិដ្ឋមួយទៀត ឬច្រើននោះ ករណីនេះគួរតែត្រូវបានបញ្ជាក់ឲ្យបានច្បាស់ និងជាក់លាក់។ ផ្ទុយទៅវិញ ដីកាដំណោះស្រាយ បានលើកឡើងដោយមានការភ័ន្តច្រលំថាលោក អៀង សារី បានប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗដែលមានក្នុងដីកាដំណោះស្រាយ តាមរយៈការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម[62] (ដោយខកខានមិនបានកត់សម្គាល់ថា សហឧក្រិដ្ឋកម្មរួមមិនមែនជាទម្រង់ដែលមានសុពលភាពសម្រាប់ឧក្រដិដ្ឋកម្មថ្នាក់ជាតិដែលបានចោទប្រកាន់) ហើយដីកានេះក៏បាលើកឡើងដោយមានការភ័ន្តច្រលំផងដែរថាលោក អៀង សារី អាចទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភយ៉ាងធ្ងន់ធ្ងរតាមរយៈការរៀបចំផែនការ ញុះញង់ បញ្ជា និងជួយ និងជម្រុញ[63]។

## III. សំណើ

**ដូច្នេះ** អាស្រ័យលើមូលហេតុទាំងអស់ដែលបានលើកឡើងក្នុងសំណើនេះ មេធាវីការពារក្ដីសូមស្នើដោយក្ដីគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាលុបចោលផ្នែកខាងក្រោមនេះចេញពីដីកាដំណោះស្រាយ៖

---

[58] សាលក្រមរបស់អង្គជំនុំជម្រះលើករណី *Brđanin* , កថាខណ្ឌទី២៦៨, សូមមើលផងដែររឿងក្តីរដ្ឋអាជ្ញា តទល់នឹង *Kordić & Čerkez*, IT-95-14/2-T, សាលក្រម, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១, កថាខណ្ឌទី៣៨៦៖ "បុគ្គលម្នាក់ដែលគេរកឃើញថាបានប្រព្រឹត្តបទឧក្រិដ្ឋ នឹងទទួលខុសត្រូវពីបទរៀបចំផែនការបទឧក្រិដ្ឋដូចគ្នា"។

[59] សាលដីកាលើបណ្តឹងឧទ្ធរណ៍ *Blaškić,* កថាខណ្ឌទី៩១ ដល់ ៩២, សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Kvočka,* កថាខណ្ឌទី១០៤។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង *Kordić & Čerkez* IT-95-14/2-A, សាលដីកាលើបណ្តឹងឧទ្ធរណ៍, ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥, កថាខណ្ឌទី៨១ ដល់ ៨២, ៩១។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង* *Milutinović et al.*, IT-05-87-T, សាលដីកា, ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩, កថាខណ្ឌទី៧៧។

[60] សាលក្រមរបស់អង្គជំនុំជម្រះករណី *Stakić*, កថាខណ្ឌទី៤៤៥។

[61] រឿងក្តីរដ្ឋអាជ្ញាតទល់នឹង*Simić et al.*, IT-95-9-T, សាលក្រម, ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣, កថាខណ្ឌទី១៣៨៖ "អង្គជំនុំជម្រះតុលាការកំពូល នៅពេលថ្មីៗនេះ បញ្ជាក់ថាជនជាប់ចោទដែលត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ត្រូវតែចាត់ទុកថាបានប្រព្រឹត្តឧក្រិដ្ឋកម្មនោះ គឺមិនចាត់ទុកថាបានជួយ និងជម្រុញឡើយ។ ម្យ៉ាងវិញទៀត ការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃ ការប្រព្រឹត្តបទឧក្រិដ្ឋរួមគ្នា"។

[62] ដីកាដំណោះស្រាយ, កថាខណ្ឌ១៥៤០។

[63] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី១៥៤៥, ១៥៤៨,១៥៥១,១៥៥៤។

ក. ការយោងទាំងអស់ទាក់ទងនឹងឧក្រិដ្ឋកម្មថ្នាក់ជាតិ។

ខ. ការយោងទាំងអស់ទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ឬជម្រើសផ្សេងពីនេះ**កែប្រែ** ដីកាដំណោះស្រាយ ដើម្បីបង្ហាញថាអំពើប្រល័យពូជសាសន៍តាមរយៈការប្រព្រឹត្តដោយផ្ទាល់ និងតាមការឃុបឃិត ត្រូវបានដកចេញ។

គ. កថាខណ្ឌពី ១៣៩៧ ដល់ ១៤០១ ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការយោងទាំងអស់ដល់ការធ្វើទុក្ខបុកម្នេញថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ឃ. រាល់ការយោងទាំងអស់ទាក់ទងនឹងការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ។

ង. រាល់ការយោងទាំងអស់ទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម។

ច. រាល់ការយោងទាំងអស់ទាក់ទងនឹងការរៀបចំផែនការ ញុះញង់ ជួយ និងជម្រុញ និងបញ្ជា។

សូមលោកចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៤** ខែ **កុម្ភៈ** ឆ្នាំ **២០១១**

**អាង ឧត្តម** **Michael G. KARNAVAS**

សហមេធាវីរបស់លោក **អៀង សារី**